**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ១៥២ MOC / M 2003

# ប្រកាស

## ស្តីពីការបង្កើតបន្ថែមការិយាល័យពីរចំណុះ នាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម
- យោងលិខិត លេខ ១០៩៣ សជណ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការបង្កើតមជ្ឈមណ្ឌលទំនាក់ទំនង ផ្តល់ពត៌មានសំរាប់អនុវត្តកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មអន្តរជាតិ
- តាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## <u>សំរេច</u>

**<u>ប្រការ១</u> :**

បង្កើតការិយាល័យចំនួន ០២ ស្ថិតក្រោមនាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ :

១- ការិយាល័យផ្តល់ ទទួលពត៌មានសេវាកម្ម

២- ការិយាល័យផ្ទៀងផ្ទាត់ភាពស្របគ្នានៃច្បាប់ និងបទប្បញ្ញត្តិ នៃអង្គការពាណិជ្ជកម្មពិភពលោក

**<u>ប្រការ២</u> :**

ការិយាល័យផ្តល់ ទទួលពត៌មានសេវាកម្ម មានភារកិច្ច :

- ប្រមូលផ្តុំពត៌មានសេវាកម្ម ពីអន្តរក្រសួងពាក់ព័ន្ធ ដើម្បីបញ្ជូនទៅ លេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោកជាប្រចាំ
- សហការជាមួយការិយាល័យផ្ទៀងផ្ទាត់ភាពស្របគ្នានៃច្បាប់ និងបទប្បញ្ញត្តិ នៃអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីផ្តល់យោបល់លើអត្ថបទច្បាប់ និងលិខិតបទដ្ឋានដែលទាក់ទងដល់សេវាកម្ម
- សំរបសំរួល និងផ្សព្វផ្សាយការអនុវត្តន៍រាល់ការងារសេវាកម្មដល់វិស័យឯកជន និងស្ថាប័នពាក់ព័ន្ធ
- សហការណ៍ជាមួយការិយាល័យអង្គការពាណិជ្ជកម្មពិភពលោកដើម្បីប្រមូលផ្តុំ និង ចងក្រងឯកសារសំរាប់ការចរចាដោះស្រាយរាល់បណ្តឹងតវ៉ាលើការអនុវត្តន៍ច្បាប់ និងលិខិតបទដ្ឋានរបស់កម្ពុជា ដែលទាក់ទងនឹងការងារសេវាកម្ម ។

**ប្រការ៣ :**

ការិយាល័យផ្ទៀងផ្ទាត់ភាពស្របគ្នា នៃច្បាប់ និងបទបញ្ញត្តិនៃអង្គការពាណិជ្ជកម្មពិភពលោក មានភារកិច្ច :

- ត្រួតពិនិត្យលើភាពស្របគ្នា និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានដែលទាក់ទងដល់កិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក សន្ធិសញ្ញា និងកិច្ចព្រមព្រៀងនានា ដែលពាក់ព័ន្ធនឹងការងារពាណិជ្ជកម្ម
- ប្រមូលផ្តុំនិងផ្តល់ពត៌មានអំពីច្បាប់និងលិខិតបទដ្ឋានរបស់កម្ពុជាជូនអង្គការពាណិជ្ជកម្មពិភពលោកជាប្រចាំ
- ទុកដាក់ និងថែរក្សានូវឯកសារដែលទទួលពីអង្គការពាណិជ្ជកម្មពិភពលោក និងពីក្រសួងនានា
- សំរបសំរួលជាមួយការិយាល័យអង្គការពាណិជ្ជកម្មពិភពលោកក្នុងការផ្តល់យោបល់លើសេចក្តីព្រាងច្បាប់លិខិតបទដ្ឋានរបស់កម្ពុជា
- សំរបសំរួល និងផ្សព្វផ្សាយការអនុវត្តន៍កិច្ចព្រមព្រៀង សន្ធិសញ្ញាពាណិជ្ជកម្ម ដល់ស្ថាប័នរដ្ឋ និងវិស័យឯកជន ។

**ប្រការ៤ :**

ការិយាល័យផ្តល់ ទទួលពត៌មានសេវាកម្ម និង ការិយាល័យផ្ទៀងផ្ទាត់ភាពស្របគ្នា នៃច្បាប់និងបទបញ្ញត្តិ នៃអង្គការពាណិជ្ជកម្មពិភពលោក ដឹកនាំតាមការិយាល័យនីមួយៗដោយប្រធានការិយាល័យមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ៥ :**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៦ :**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានអាស៊ាននិងអង្គការអន្តរជាតិ ប្រធាននាយកដ្ឋានបុគ្គលិក ត្រូវអនុវត្តប្រកាសនេះ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០០៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់នាយកដ្ឋាន មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ